# SNAP-BB Senior Insert - Khmer

## តើ SNAP ជាអ្វី?

កម្មវិធីជំនួយបន្ថែមអាហារមានជីវជាតិ (Supplemental Nutrition Assistance Program) ជួយបុគ្គលម្នាក់ៗ និងគ្រួសារមានប្រាក់ចំណូលតិច ដើម្បីទិញម្ហូបអាហារល្អ មានជីវជាតិ។ អ្នកអាចនឹងមានសិទ្ធិទទួល SNAP - សូមអានខាងក្រោម ដើម្បីឲ្យបាន ជ្រាបថែមទៀត!

## ការដាក់ពាក្យសុំងាយស្រួលជាង សំរាប់ព្រឹទ្ធាវ័យ!

ព្រឹទ្ធាវ័យអាចដាក់ពាក្យសុំអត្ថប្រយោជន៍ SNAP ដោយប្រើក្រដាសបំពេញទំរង់ខ្លីជាង។ ការដាក់ពាក្យសុំ SNAP សំរាប់ចាស់ទុំ (Elder SNAP Application) មានសំណួរតិចជាង និងងាយស្រួលអានជាង។

បន្ទាប់មក អ្នកចាត់ចែងករណី SNAP នឹងទូរស័ព្ទមកអ្នក ដើម្បីគ្រោងពេលការធ្វើសំភាសន៍ ដើម្បីនិយាយជាមួយអ្នក អំពីការដាក់ពាក្យសុំរបស់អ្នក។ **សូមកុំភ្លេចដាក់លេខទូរស័ព្ទរបស់អ្នក នៅលើពាក្យសុំ SNAP។**

ភស្តុតាងណាមួយ ដែលអ្នកចាត់ចែងករណីរបស់អ្នកស្នើសុំ ដូចជាអ្វីៗដែលមានឈ្មោះ និងអាសយដ្ឋានរបស់អ្នក ឬលេខសន្តិសុខសង្គម និងវិក្កយប័ត្រពេទ្យរបស់អ្នក អាចផ្ញើទៅឲ្យអ្នកចាត់ចែងករណី SNAP របស់អ្នក បន្ទាប់ពីការសំភាសន៍អ្នក។

## តើខ្ញុំអាចមានទ្រព្យសម្បត្តិ និងនៅតែអាចដាក់ពាក្យសុំ SNAP បានឬទេ?

អ្នកអាចមានផ្ទះ កម្មសិទ្ធិផ្ទាល់ខ្លួន រថយន្ត របស់អ្នក និងមានប្រាក់កាសនៅក្នុងធនាគារ។

បើអ្នកជាព្រឹទ្ធាវ័យ រស់នៅតែម្នាក់ឯង ហើយប្រាក់ចំណូលសរុប (ចំនួនរួម) ជាប្រចាំខែរបស់អ្នក គឺ $1,915 ឬតិចជាង អ្នកនឹងមិនបានតម្រូវឲ្យផ្តល់ព័ត៌មាន និងភស្តុតាង សំរាប់ធនធាននៃក្រុមគ្រួសាររបស់អ្នកទេ ដូចជាកុងធនាគាររបស់អ្នក ឬវត្ថុមានតម្លៃផ្សេងៗទៀតទេ។

បើអ្នកជាព្រឹទ្ធាវ័យ រស់នៅជាមួយនឹងប្តីប្រពន្ធរបស់អ្នក ហើយប្រាក់ចំណូលសរុបរួមគ្នា (ចំនួនរួម) ជាប្រចាំខែរបស់អ្នក គឺ $2,585 ឬតិចជាង អ្នកនឹងមិនបានតម្រូវឲ្យផ្តល់ព័ត៌មាន និងភស្តុតាង សំរាប់ធនធាននៃក្រុមគ្រួសាររបស់អ្នកទេ។

បើអ្នកជាព្រឹទ្ធាវ័យ ហើយប្រាក់ចំណូលសរុប (ចំនួនរួម) របស់អ្នក គឺខ្ពស់ជាងចំនួនដែលចុះរាយនៅខាងលើ អ្នកនឹងមានកំរិត $ 3,250 ទៅលើធនធាននៃក្រុមគ្រួសារ ដែលអ្នកអាចមាន និងនៅតែអាចទទួល SNAP បាន។ នេះមានន័យថា អ្នកនឹងបានសូមឲ្យផ្តល់ព័ត៌មាន និងភស្តុតាង សំរាប់ធនធាននៃក្រុមគ្រួសាររបស់អ្នក។

អ្នកមិនបាច់ទៅកាន់ការិយាល័យ SNAP ដើម្បីដាក់ពាក្យសុំទេ។

ផ្ញើក្រដាសដាក់ពាក្យសុំដែលបានបំពេញចប់គ្រឡប់ទៅ : DTA Document Processing Center, P.O. Box 4406, Taunton MA 02780-0420។

*សារៈសំខាន់ : បុគ្គលិកនៅ ក្រុមប្រឹក្សាស្តីពីជរាវ័យ, វឌ្ឍនកម្មទីលំនៅព្រឹទ្ធាវ័យ (Councils on Aging, Senior Housing Development), មជ្ឈមណ្ឌលសុខភាព និងអង្គការតាមសហគមន៍ផ្សេងៗទៀត អាចជួយអ្នកដាក់ពាក្យសុំអត្ថប្រយោជន៍ SNAP បាន!*

ទូរស័ព្ទទៅលេខ **1-866-950-FOOD**
ថ្ងៃច័ន្ទ រហូត ថ្ងៃសុក្រ
ពីម៉ោង 8:45 ព្រឹក - 5:00 ល្ងាច
ឬមើល **www.mass.gov/dta**